# ការសំភាសន៍របស់អ៊ុំ សោម សារ៉ន

កៈ អ្នកដែរសំភាសន៍ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ សោម សារ៉ន

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើព្វយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ នឹងហើយ

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី18 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិអំពិលលើ នៅឃុំអីគេដែរអ៊ុំ?

ខៈ ឃុំអំពិលលើដែរ

កៈ ចឹងឃុំអំពិលលើដែរហោសអ៊ុំ?

ខៈ នឹងហើយនៅស្រុកកំពុងសៀម

កៈ នឹងស្រុកកំពុងសៀម ខេត្តកំពង់ចាម ចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំមានឈ្មោះ សោម សារ៉ន

កៈ ប៉ុន្តែមានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខ៖ គេចេះតែដាក់ផ្តេសផ្តាស់នឹង ប៉ុន្តែដាក់តែឈ្មោះសោម សារ៉ននឹង

ក៖ ចុះកាលពីក្មេងនឹងមានធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងពីនឹងទេ?

ខ៖ ឈ្មោះនឹងដដែរនឹង

ក៖ ចឹងមានតែឈ្មោះមួយនឹងដដែរទេហោសអ៊ុំ?

ខ៖ ចា៎!មានឈ្មោះរ៉ននឹងដដែរនឹង

ក៖ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ68ឆ្នាំនឹង

ក៖ ចុះអ៊ុំមានចងចាំថ្ងៃខែឆ្នាំកំណើតដែរអ៊ុំកើតដែរទេ?

ខ៖ នៅថ្ងៃទី22 ខែ 5 ឆ្នាំ1950

ក៖ ចុះឆ្នាំច័ន្ទគតិអ៊ុំឆ្នាំអីគេដែរអ៊ុំ?

ខ៖ ខ្ញុំឆ្នាំខាល

ក៖ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំកើតនៅស្រុកត្បូងឃ្មុំ

ក៖ ប៉ុន្តែនៅភូមិអី ឃុំអី ស្រុកអីគេដែរអ៊ុំ?

ខ៖ នៅភូមិគរ ស្រុកត្បូងឃ្មុំ

ក៖ ចុះឃុំអីគេដែរអ៊ុំ?

ខ៖ ឃុំគរនឹងណា

ក៖ ភូមិគរ ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ណាអ៊ុំ?

ខ៖ នឹងហើយចឹងនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នឹងភូមិយើងចាស់ដែរយើងកើតនឹង

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ចុះស្លាប់យកដែរទេ?

កៈ បាទយកទាំងអស់នឹង?

ខៈ ទាំងអស់មាន4នាក់

កៈ ចុះមានស្រីប៉ុន្មាននាក់ ហើយនឹងមានប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ មានស្រី3នាក់ នឹងប្រុសមួយនាក់

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ អ៊ុំជាកូនពៅគេនឹង

កៈ ចុះអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនរបស់អ៊ុំខ្លះៗបានដែរទេអ៊ុំ?

ខៈ បានតើ!

កៈ ចុះបងគេមានឈ្មោះអីគេដែរអ៊ុំ?

ខៈ បងគេមានឈ្មោះសា រឿន

កៈ ចុះបងទី2វិញអ៊ុំ?

ខៈ មានឈ្មោះសា មឿន

កៈ ចុះបងទី3ហោសអ៊ុំ?

ខៈ មានឈ្មោះកាហាន

កៈ បន្ទាប់មកបានអ៊ុំ?

ខៈ នឹងហើយបន្ទាប់មកបានខ្ញុំ

កៈ ចុះមានស្លាប់ប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ មានស្លាប់3នាក់ នៅសល់តែ2នាក់ទេ

កៈ ចុះចឹងមានន័យថាមាន5នាក់ហោសអ៊ុំ?

ខៈ ហ៊ោ!ចាំគិតមើលសិន មានតែ4នាក់ទេ ស្លាប់2នាក់ នឹងនៅ2នាក់នឹង

កៈ អូ៎!ចឹងនៅតែ2នាក់ទេណាអ៊ុំ?

ខ៖ ចាំ!នៅបងស្រីខ្ញុំមួយនឹងនៅបន្ទាប់ខ្ញុំរាល់ថ្ងៃនឹង

ក៖ ចុះអ៊ុំធ្លាប់មានចងចាំអនុស្សាវរីយ៍អីទេ
កាលពីអ៊ុំនៅជាមួយបងប្អូនរបស់អ៊ុំកាលពីនៅក្មេងៗហាសអ៊ុំ?

ខ៖ អូ៎!ភ្លេចអស់ហើយនឹង

ក៖ ប៉ុន្តែអ៊ុំគិតថាធ្លាប់លេងឡឹកបាយឡអីទេ?

ខ៖ អើរនឹងចេះតែមានហើយនឹងលេងឡឹកបាយឡ លេងខ្វងអីនឹងមាន

ក៖ មានលេងខ្វង លេងថុយអីមានទេ?

ខ៖ នឹងហើយលេងបិទពួនអីនឹងកាលពីនៅក្មេងៗនឹងមានមិនដែរអត់ទេនឹង

ក៖ ចុះមានដែរលេងវៃគ្នាអីទេអ៊ុំ?

ខ៖ ថាម៉េចគេ?

ក៖ មានធ្លាប់លេងវៃគ្នាអីទេអ៊ុំ?

ខ៖ អត់ទេមិនដែរទេនឹង ខ្ញុំមិនដែរទេនឹងនោះ

ក៖ ចុះអ៊ុំចូលចិត្តលេងអីគេជាបងប្អូនរបស់អ៊ុំកាលពីនៅក្មេងដែរអ៊ុំ?

ខ៖ លេងពួន នឹងលេងឡឹកបាយឡនឹង ហើយបានតែដណ្តើមគ្នានឹង មិនដែរវៃគ្នាទេនឹង

ក៖ បាទអ៊ុំ!បងប្អូនរបស់អ៊ុំនឹងគាត់នៅណាដែរសព្វថ្ងៃនឹង?

ខ៖ នៅភូមិគរនឹង

ក៖ បងរបស់អ៊ុំមែនទេអ៊ុំ?

ខ៖ ស្លាប់អស់ហើយនឹងហោស

ក៖ គ្រាន់បងរបស់អ៊ុំនឹងនៅសល់មួយមែនទេអ៊ុំ?

ខ៖ នឹងហើយនៅភូមិគរនឹង

ក៖ ចុះគាត់ធ្វើអីគេដែរនៅភូមិគរនឹងដែរអ៊ុំ?

ខ៖  គាត់ធ្វើស្រែនឹង គេមានកូនច្រើនណាស់កូនគេ8នាក់ហោសបងរបស់ខ្ញុំនឹងហោស

ក៖  ចុះឪពុករបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  គាត់មានឈ្មោះ ឆាន់ ម៉ែឈ្មោះទូច

ក៖  ចុះគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខ៖  កាលពីគាត់ស្លាប់នឹងអាយុ90ឆ្នាំ

ក៖  ប៉ុន្តែដូចជាគាត់ស្លាប់ប៉ុន្មានឆ្នាំដែរហើយអ៊ុំ?

ខ៖  ហោ!ស្លាប់យូរដែរហើយនឹងប៉ុន្មានឆ្នាំទេ
តាំងពីឆ្នាំ2006ហោសរហូតមកដល់ឥឡូវនឹងប៉ុន្មានឆ្នាំដែរ

ក៖  គាត់ស្លាប់អស់12ឆ្នាំនឹងអ៊ុំ

ខ៖  តាំងពីខ្ញុំនឹងនៅមាត់ទន្លេនឹង

ក៖  ចឹងគាត់អាយុ90ឆ្នាំវាឡើងបាន102ឆ្នាំអ៊ុំ?

ខ៖  នឹងហើយប៉ុណ្ណឹង

ក៖  ប៉ុន្តែម្ដាយរបស់អ៊ុំ នឹងឪពុករបស់អ៊ុំនឹងខុសគ្នាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖  ម្ដាយរបស់ខ្ញុំនឹងបងគាត់

ក៖  ចឹងម្ដាយរបស់អ៊ុំនឹងបងឪពុករបស់អ៊ុំនឹងប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖  គាត់ឆ្នាំកោរ មើលជូត ឆ្លូវ ខាល ថោះ រោង គាត់បង6ឆ្នាំនឹង

ក៖  គាត់បង6ឆ្នាំចឹងមានន័យថាគាត់អាយុ108ឆ្នាំហើយចឹង?

ខ៖  នឹងហើយចឹង

ក៖  ចុះឪពុករបស់អ៊ុំនឹងគាត់កើតនៅណាដែរអ៊ុំ?

ខ៖  ខ្ញុំអត់ដឹងផងនឹង

ក៖  ចុះម្ដាយរបស់អ៊ុំវិញគាត់កើតនៅណាដែរ?

ខ៖  ខ្ញុំកើតមកឃើញគាត់នៅភូមិគរ ស្រុកត្បូងឃ្មុំនឹងតែម្តងនឹង

ក៖  ចុះឪពុករបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  គាត់ធ្វើតែស្រែនឹង

ក៖  អូ្ហ!ចឹងឡូគាត់ធ្វើតែស្រែទេហោសអ៊ុំ?

ខ៖  កាលពីក្មេងខ្ញុំទាន់គាត់ឡើងដើមត្នោត

ក៖  បាទអ៊ុំចឹងគាត់មានធ្វើអីផ្សេងទៀតទេអ៊ុំ?

ខ៖
អត់មានទេមានតែ2មុខនឹងរួចពីធ្វើស្រែគាត់ឡើងដើមត្នោតយកស្ករទៅដោះស្រាយជីវភាព
ដើម្បីយក ទៅចិញ្ចឹមកូនអីចឹងទៅណាស់

ក៖  ចុះឪពុករបស់អ៊ុំនឹងគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖  គាត់ស្លូតមិនដែរវៃកូនទេនឹង

ក៖  ប៉ុន្តែម្តាយរបស់អ៊ុំគាត់កាចហោសអ៊ុំ?

ខ៖  ម៉ែកាចម៉ែវៃដូចថាយើងកុហកគាត់ចឹងទៅ
ដូចថាយើងចង់ទៅលេងផ្ទះណុងចឹងទៅប៉ុន្តែគាត់មិន
អោយទៅទេដឹងតែមកវិញត្រូវហើយនឹង
ដូចថាមិនវៃច្រើនទេដូចថាវៃមួយម៉ូងទៅពីរម៉ូងចឹងទៅណាស់

ក៖ ចឹងហោសអ៊ុំ?

ខ៖  ដូចថាផ្ទះណុងអញ់មិនអផយហាងទៅកុំទៅនៅយើងនៅក្មេងៗទេណាស់
ដូចថាក្មេងៗកូនគេ នឹងកូនយើងទៅលេងជាមួយគ្នាចឹងទៅណាស់ នឹងគ្រាន់តែប៉ុណ្ណឹង

ក៖  ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  ធ្វើតែស្រែដូចខ្ញុំថាចឹងនឹង

ក៖  អូ្ហ!ចឹងឪពុករបស់អ៊ុំ នឹងម្តាយរបស់អ៊ុំធ្វើស្រែដូចតែគ្នាទេ?

ខ៖  នឹងហើយធ្វើតែស្រែដូចតែគ្នាទេ

ក៖  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំហាស
កាលពីអ៊ុំនៅក្មេងហាសអ៊ុំធ្លាប់ចងចាំអនុស្សាវរីយ៍អីទេអ៊ុំ?

ខ៖  ចង់និយាយពីអីដែរអានឹង?

ក៖  ចង់និយាយថាកាលពីអ៊ុំនៅជាមួយពួកគាត់ហាស
កាលពីអ៊ុំនៅក្មេងៗហាសអ៊ុំធ្វើលេងអីជាមួយគាត់ រឺអ៊ុំទៅធ្វើស្រែអីជាមួយគាត់ដែរចឹង
រឺក៏អ៊ុំទៅធ្វើម្ហូបជាមួយឪពុកម្ដាយរបស់អ៊ុំចឹងហាសមានដែរទេ?

ខ៖  មានដែរនឹង

ក៖  មានធ្វើអីគេខ្លះដែរអ៊ុំ?

ខ៖  យើងដាំស្លអោយគាត់ហូបអីចឹងទៅ
ហើយយើងទៅស៊ីឈ្នួលពេលដែរយើងហើយចឹងទៅយើងទៅ ស៊ីឈ្នួយលគេហាស

ក៖  បាទចឹងអ៊ុំ?

ខ៖  ខ្ញុំកាលណុងមួយថ្ងៃនឹងបាន25រៀល

ក៖  បាន25រៀលហោសអ៊ុំ?

ខ៖
ចុះដូចយើងឥឡូវនឹងហោសហើយបានមកអោយម៉ែអស់ៗចឹងទៅពេលដែរយើងធ្វើបុណ្យទានចឹង
ទៅយើងទៅសុំពីគាស់វិញចឹងទៅគាត់អោយមកវិញចឹងទៅប៉ុន្តែអោយមិនច្រើនទេអោយ5រៀល រឺក៏10រៀលនឹងអោយចាយ

ក៖  អូ៎!ចឹងហោសអ៊ុំ?

ខ៖  នឹងជីវភាពរបស់ខ្ញុំនឹងហាស ហើយបើនិយាយពីស្រូវអីក៏មិនខ្វះស៊ីដែរនឹង
យើងធ្វើហាសមានស្រូវអី មិនខ្វះទេនឹង

ក៖ បាទចឹងអ៊ុំ?

ខ៖
ពេលដែរខ្ញុំមករស់នៅនេះកាលណុងឆ្នាំ1971ខ្ញុំយកតានឹងនៅឆ្នាំ1971នឹងនៅជំនាន់លុន ណុលចឹង បាស ហើយខ្ញុំចេញពីស្រុកនៅឆ្នាំ1970

ក៖ ហើយយកតាវិញ?

ខ៖ នៅឆ្នាំ1971នឹង

ក៖ ចឹងយកតានៅឆ្នាំ1971ហោសអ៊ុំ?

ខ៖ នឹងហើយនៅឆ្នាំ1971ពេលដែរខ្ញុំយកតានឹងបាស

ក៖ អ៊ុំ!ចឹងហោសអ៊ុំ?

ខ៖ រួចទៅបានកូននឹង4នាក់នឹងបានស្រី2នាក់ នឹងប្រុស2នាក់នឹង

ក៖ បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់មានដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខ៖ អត់ដែរនិយាយអីផងនឹង អត់ដែរទេនឹងអត់ដែរទេនឹង

ក៖ ចុះម្ដាយរបស់អ៊ុំវិញគាត់មានដែរប្រាប់ទេអ៊ុំ?

ខ៖ អត់ដែរទេខ្ញុំកើតមកឃើញគាត់នៅភូមិនឹងតែម្ដងនឹង

ក៖ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខ៖ ខ្ញុំអត់ស្គាល់សោះ

ក៖ ប៉ុន្តែអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ស្គាល់តើ!

ក៖ គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ មានឈ្មោះតាទូច យាយអ៊ុច

ក៖ ចុះយាយតាខាងម្ដាយអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតាខាងម្ដាយអត់ស្គាល់សោះនឹង

ក៖ ចុះយាយអ៊ុំអត់ស្គាល់ដែរ?

ខ៖ ខ្ញុំស្គាល់តែខាងឪពុកទេនឹងឈ្មោះតាទូច យាយអ៊ុចនឹង
បើខាងម៉ែនឹងអត់ស្គាល់ទេចុះគាត់មិនដែរ និយាយផងនឹងបើខ្ញុំកើតមកមិនទាន់ទេនឹង

ក៖ អូ៎!ចឹងហោសអ៊ុំ?

ខ៖ យាយតាខាងឪពុកនឹងក៏កើតមកមិនទាន់ដែរប៉ុន្តែគ្រាន់តែស្គាល់ឈ្មោះនឹង

ក៖ ចុះយាយតាខាងឪពុកនឹងគាត់កើតនៅណាអ៊ុំមានដឹងទេ?

ខ៖ នៅភូមិនឹងដែរ នៅភូមិគរស្រុកត្បូងឃ្មុំនឹងដែរនឹង

ក៖ ចុះយាយតាខាងម្ដាយអ៊ុំមានដឹងទេ?

ខ៖ ខ្ញុំមិនដឹងទេចុះពេលណុងយើទៅនៅផ្ដេសផ្ដាស់នឹង
ហើយគាត់ថាម៉ែឪគាត់នឹងមិនដឹងថានៅណាអី
នៅណីទេគាត់ចេះតែតាមគេតាមឯងចឹងទៅណាស់ ហើយមកការនៅពុកខ្ញុំនឹងណាស់
ម៉ែឪគាត់នឹងមិនដឹងថានៅណាផងនឹងគាត់មិនស្គាល់ដែរនឹង

ក៖ អូ៎!ចឹងចុះអ៊ុំមករស់នៅខេត្តនឹងយូរដែរនៅអ៊ុំ?

ខ៖ ខ្ញុំមកនៅជំនាន់តាបន្ទាយធ្វើជាចៅហ្វាយខេត្តហោស

ក៖ ថាម៉េចដែរអ៊ុំ?

ខ៖ ជំនាន់តាបន្ទាយនឹងជាចៅហ្វាយខេត្តនឹងនៅឆ្នាំណាខ្ញុំភ្លេចបាត់ហើយនឹង

ក៖ ខ្ញុំអត់ស្គាល់ផងនឹង?

ខ៖ ចាំមើលខ្ញុំនឹកសិននឹងអូនៅឆ្នាំ1979នឹងយើងដាក់ឆ្នាំ1979ចុះ

ក៖ អូ៎!ដែរអ៊ុំមកនៅខេត្តនៅតែម្ដងនឹង?

ខ៖ នឹងហើយអស់ប៉ុណ្ណឹង

ក៖ ចឹងមានន័យថាអស់រយះពេល39ឆ្នាំហើយនឹងចឹង?

ខ៖ នឹងហើយៗនៅកំពង់ចាមនឹងតែម្ដងនឹង

កៈ ចុះអ៊ុំមានកូនចៅណាដែររស់នៅក្រៅប្រទេសក្រៅពីស្រុកខ្មែរទេអ៊ុំ?

ខៈ អត់មានទេ

កៈ នៅថៃ វៀតណាមអីក៏អត់មានដែរ?

ខៈ អត់មានទេនៅស្រុកខ្មែរទាំងអស់នឹង

កៈ ចុះស្វាមីរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់នឹងឈ្មោះកុល សាវេន

កៈ ចុះអ៊ុំមានចងចាំអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខៈ យើងរៀបជំនាន់លុនណុលនឹងចាប់ដៃគ្នានឹង

កៈ អូ៎!ប្រហែលជាឆ្នាំណាដែរអ៊ុំមានចងចាំទេ?

ខៈ នៅក្នុងឆ្នាំ1971នឹង

កៈ អូ៎!ចឹងនៅឆ្នាំ1971ណាអ៊ុំ?

ខៈ ចា៎!នឹងហើយឆ្នាំនឹងឯង នឹងចាប់ដៃគ្នានឹងដូចអាពតនឹងដែរ

កៈ នៅឆ្នាំនឹងអ៊ុំ?

ខៈ នឹងហើយនៅពេលដែរឆ្នាំ1972នឹងខ្ញុំបានអាបងគេនឹង

កៈ ចឹងអ៊ុំការអស់47ឆ្នាំហើយអ៊ុំ?

ខៈ នឹងហើយប៉ុណ្ណឹងចាប់ដៃគ្នាដូចយើងចង់ចូលអាពតហើយនឹង

កៈ ចុះពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯង រឺម្តាយឪពុករបស់អ៊ុំគាត់ជា អ្នករៀបអោយដែរអ៊ុំ?

ខៈ ម៉ែឪមិនដឹងទេថាកូនអង្គការហោស អង្គការជាអ្នករៀបចំអោយទាំងអស់នឹង

កៈ ចុះពេលដែរអ៊ុំប្រុសមកចូលស្ដីដណ្ដឹងអ៊ុំនឹងមានជាជំនូនដែរទេអ៊ុំ?

ខៈ អត់មានទេ

កៈ ជាថ្លៃទឹកដោះអីក៏អត់មានដែរ?

ខៈ អត់មានទេនឹង ចុះកាលណុងគេមិនទាន់ចាយលុយផងនឹង

កៈ អូ!គេមិនទាន់ចាយ់លុយទេណាអ៊ុំ?

ខៈ គ្មានទេពេលណុង

កៈ ចុះជុំគិតថាពេលណាដែរអ៊ុំគិតថាអ៊ុំប្រុសស្រលាញ់អ៊ុំដែរនឹង
ហើយប្រហែលជាប៉ុន្មានឆ្នាំដែរគាត់ ចូលស្តីដណ្តឹងចឹងហាសអ៊ុំ?

ខៈ គ្មានប៉ុន្មានឆ្នាំទេគ្រាន់តែយើងឃើញគ្នាចឹងទៅ
ហើយគាត់ថាស្រលាញ់ចឹងទៅហើយគេអោយយើង
ចាប់ដៃគ្នាទៅចុះថ្ងៃណុងគេរៀនហោស

កៈ អូ!បាទអ៊ុំ?

ខៈ គេរៀនបើកសាលាមួយធំ ហើយប្រកាសចាប់ដៃគ្នាជាប្តីប្រពន្ធទៅរួចគ្នាហើយនឹង
ហើយយើងប្តេជ្ញាអោយគេទៅនឹង

កៈ អូ!ចឹងស្រួលអ៊ុំ?

ខៈ កាលជំនាន់ណុងគេធ្វើចឹង

កៈ ចុះអ៊ុំចេះអាន រឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខៈ ចេះសរសេរមិនច្បាស់ទេឥឡូវនឹងយើងងងឹតភ្នែកហើយនឹង
យើងចាស់ហើយចឹងយើងងងឹតហើយ នឹងបើពីមុនអាចសរសេរបាន ឥឡូវនឹងអត់ទេ

កៈ ចុះអ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ ម៉ែឪមិនអោយរៀនទេកាលពីជំនាន់ខ្ញុំនឹងហោស

កៈ ប៉ុន្តែអ៊ុំបានរៀននៅពេលណាដែរអ៊ុំ?

ខៈ
មករៀនបានតាមបងប្រុសរបស់ខ្ញុំនឹងកាលពីគាត់មិនទាន់ស្លាប់នឹងគាត់នៅបួសធ្វើលោកនឹង

កៈ  បាទអ៊ុំរៀនតពីគាត់?

ខៈ  នឹងហើយគាត់យកអក្សរពីដើមអក្សរវត្តហោសបានយកមករៀននឹង
ហើយបងរបស់ខ្ញុំរាល់ថ្ងៃនឹង មិនចេះសោះ ងងឹតសុន្យតែម្តងនឹង

កៈ ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ  អត់ចេះទេ

កៈ  ចឹងអ៊ុំចេះតែខ្មែរមួយទេណាអ៊ុំ?

ខៈ  នឹងហើយចេះតែខ្មែរនឹង

កៈ  ចុះកាលពីអ៊ុំរៀនជាមួយបងរបស់អ៊ុំនឹងតើអ៊ុំរៀននៅណាដែរអ៊ុំ?

ខៈ  រៀននៅត្បូងឃ្មុំនឹង

កៈ  នៅខេត្តត្បូងឃ្មុំហោសអ៊ុំ?

ខៈ  នឹងហើយនៅផ្ទះបងនឹងម្តាយរបស់ខ្ញុំរាល់តែថ្ងៃនឹង

កៈ  បាទអ៊ុំចឹង?

ខៈ  បងរបស់ខ្ញុំមកបួសលោកនៅវត្តជិតនឹងណាស់ វត្តនឹងជិតទេស្មើរពីនឹងទៅថ្នល់នឹង

កៈ  ចុះអ៊ុំធ្លាប់មានមិត្តភក្តិដែរជិតស្និទ្ធិដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខៈ  ស្លាប់បាត់អស់ហើយនឹង

កៈ  ប៉ុន្តែអ៊ុំមានចងចាំឈ្មោះពួកគាត់មួយចំនួនទេអ៊ុំ?

ខៈ  អ្ហ៎!គេអោយយើងរៀបរាប់ដែរហោស

កៈ  បើអ៊ុំអាចស្គាល់អ៊ុំអាចរៀបរាប់មួយចំនួនមកអ៊ុំ?

ខៈ  ចឹងនឹងស្លាប់អស់ហើយនឹងមានឈ្មោះលាម ចឹង មីគួង មីណាង
ប៉ុន្តែស្លាប់ងស់រលីងហើយនឹង

កៈ  ប៉ុន្តែអ៊ុំមានចងចាំអនុស្សាវរីយ៍អីដូចថាអ៊ុំធ្លាប់មានធ្វើអីជាមួយគាត់ដែរទេអ៊ុំ?

ខ៖ ធ្លាប់ដើរលេងជាមួយគ្នា ធ្លាប់ទៅបុណ្យជាមួយគ្នា នឹងធ្លាប់ទៅស៊ីឈ្នួយលគេជាមួយគ្នាដែរនឹង បី បួននាក់នឹងប៉ុន្តែគេស្លាប់បាត់អស់ហើយនឹង

ក៖ បាទចឹងហោសអ៊ុំ?

ខ៖ ចឹងបានអ្នកស្រុកគេនិយាយថាមីនឹងអាយុវែងជាងគេហាសគេស្លាប់ទៅមុនទៅ ខ្ញុំថាអើរអញ់ពុងតែ ស្លាប់ទេប៉ុន្តែគ្រាន់តែមុននឹងក្រោយនឹង

ក៖ អ៊ុំនិយាយចឹងហោសអ៊ុំ?

ខ៖ នឹងហើយខ្ញុំថាចឹងណាស់ទៅស្រុកថ្ងៃមុននឹងទៅហោស ថ្ងៃភ្ជុំនឹងទៅតើ ទៅជាមួយមីនឹងនឹងប្ដីវាអី ទៅដែរនឹង

ក៖ អូ៎!ប៉ុន្តែគាត់នៅរស់ទេហោសអ៊ុំ?

ខ៖ ពីណាដែរ?

ក៖ ចុះអ៊ុំថាប្ដីនរណាគេដែរនឹង?

ខ៖ នេះមីនឹងណាស់

ក៖ អូ៎!អ៊ុំទៅជាមួយកូនរបស់អ៊ុំហោស?

ខ៖ នឹងហើយមីនឹង ទៅជាមួយប្ដីគេអាកង់បីអីនឹងជាមួយស្រីម៉ៅអីនឹងទៅ

ក៖ អូ៎! បាទអ៊ុំចឹង?

ខ៖ ប៉ុន្តែមិត្តភក្តិរបស់ខ្ញុំនឹងគេបានស្លាប់អស់ហើយនឹងគេឈឺហាស

ក៖ មិត្តភក្តិរបស់អ៊ុំបានស្លាប់អស់ហើយ?

ខ៖ នឹងហើយគេបានស្លាប់អស់ហើយនឹងបីបួននាក់នឹងស្លាប់អស់ហើយនឹង

ក៖ ចុះអ៊ុំធ្លាប់ទៅធ្វើការងារនៅវាលស្រែទេអ៊ុំ?

ខ៖ វាលស្រែហោស?

ក៖ ទៅធ្វើស្រែចំការហាសអ៊ុំធ្លាប់បានធ្វើទេអ៊ុំ?

ខ៖ ធ្លាប់ដែរតើ ស៊ីឈ្នួលគេនឹងណាស់

កៈ អ៊ូ!អ៊ុំធ្លាប់ទៅស៊ីឈ្នួលគេហោសអ៊ុំ?

ខៈ យើងមិនមានចំការ យើងមានតែស្រែទេណាស់

កៈ ចឹងអ៊ុំមានតែស្រែទេ?

ខៈ នឹងចឹងទៅយើងគ្មានចំការយើងទៅស៊ីឈ្នួលគេចឹងទៅ ច្រូតល្ង បេះសណ្តែកអីនឹង នឹងដកសណ្តែកដីអីនឹងដៃរខ្ញុំថាបាន25រៀលនឹងណាស់

កៈ អ៊ូ!អ៊ុំនិយាយមិញនឹងហោសអ៊ុំ?

ខៈ នឹងហើយជំនាន់ណុងហោសជំនាន់យើងពីដើមនឹងណាស់
នេះមាសជំនាន់ខ្ញុំនឹង150ទេ

កៈ ថោកហាសណាអ៊ុំ?

ខៈ នឹងហើយកាលពីជំនាន់ណុងនឹង

កៈ ចុះកាលពីពេលណុងគេចាយលុយដៃរនៅអ៊ុំ?

ខៈ
គេចាយហើយនឹងជំនាន់សម្តេចសីហានុនឹងគេចាយហើយនឹងដៃរគេហៅសង្គមរាស្រ្តនិយម ហោស ចឹងយើងនៅចាយលុយនឹង

កៈ ចឹងមានន័យថាយើងនៅចាយលុយធម្មតាទេនឹង

ខៈ យើងនៅចាយប៉ុន្តែកាលណុងលុយនៅថ្លៃ នឹងរបស់វាថោក

កៈ ប៉ុន្តែពេលណុងមាសអីនៅថោកណាអ៊ុំ?

ខៈ នឹងហើយនៅថោកទេ មាសមួយជី150ទេនឹងកាលពីជំនាន់នុងហាស

កៈ អ៊ូ!បើមានអ្នកទិញមាសទុកអីជឹងតែគ្រប់ទឹកហើយនឹង?

ខៈ ម៉ែរបស់ខ្ញុំនឹងដាក់រូមចាញ់បោកគេហោស ដាក់រូមរបស់ខ្ញុំអស់រលីងនឹង ខ្សែក ខ្សែដៃអីនឹង ដាក់រូមទាំងអស់នឹងហើយខ្ញុំថាម៉ែអើយម៉ែក៏ត្រង់ម្លែសនឹង

កៈ បាទអ៊ុំចឹង?

ខ៖ នឹងហើយកន្លែងណាក៏ដូចកន្លែងណាដែរមិនគេបង្កើតសហាករពួកគេចូលមកហោស ហើយយើងមិន បង្កើតសហាករហើយម្ដាយរបស់ខ្ញុំដាក់រូមអស់រលីង ទាំងចាន ឆ្នាំស្ព័ដាក់គ្មានសល់មួយទេនិយាយពីត្រង់ នៅត្រង់

ក៖ គាត់ត្រង់ពេកហោសអ៊ុំ?

ខ៖ នឹងហើយនិយាយពីដល់គាត់ស្លាប់ខ្ញុំគ្មានបានទៅណា បងរបស់ខ្ញុំគ្រាន់តែមកតាមដល់ពេលទៅដល់ នឹងគេកប់បាត់ហើយនឹង ខ្ញុំមិនបានឃើញមុខម៉ែដល់ឥឡូវនឹង

ក៖ ចុះអ៊ុំធ្លាប់ធ្វើអាជីវកម្មអីនៅក្នុងក្រុមគ្រួសារដែរទេអ៊ុំ?

ខ៖ អាជីវកម្មនៅក្នុងក្រុមគ្រួសារយើងធ្វើអីគេដែរ យើងធ្វើស្រែរឺធ្វើចំការដែរ?

ក៖ លក្ខណះលក់ដូរអីហាសអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះធ្លាប់ចិញ្ចឹមសត្វអីទេ ដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោ ចិញ្ចឹមក្របីហាសអ៊ុំ?

ខ៖ ដែរនឹងចិញ្ចឹមគោ

ក៖ ចិញ្ចឹមលក្ខណះជាខ្នាតធំ រឺចិញ្ចឹមជាលក្ខណះគ្រួសារដែរអ៊ុំ?

ខ៖ ចិញ្ចឹមជាលក្ខណះគ្រួសារនឹងមានគោពីរនឹង តែបើបងរបស់ខ្ញុំនឹងគេចិញ្ចឹមនឹង

ក៖ អូ៎!ចឹងបងអ៊ុំចិញ្ចឹមដែរ?

ខ៖ នឹងហើយជ្រូក2ក្បាល នឹងគោ3ក្បាលអីចឹងទៅនឹង

ក៖ បាទអ៊ុំចឹងហោសអ៊ុំ?

ខ៖ ពីក្មេងនឹងគេអោយមើលតែគោទេខ្ញុំនឹងហោស

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្ដូរអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ុំដែរទៅ?

ខ៖ រាល់ថ្ងៃនឹងហោស?

កៈ  បាទអ៊ុំមានអីគេដែរអ៊ុំ?

ខៈ  រាល់តែថ្ងៃនឹងយើងខ្វះជីវភាពនឹងខ្វះលុយចាយអីនឹងសំរាប់យើង
កូននឹងដូចថាពឹងវាមិនបានហាស រាល់ថ្ងៃនឹង

កៈ  អូ៎!បាទអ៊ុំបាទ?

ខៈ  ដូចអានឹងពឹងបានហោសវាមិនដឹងថាទៅរកអីផងនឹង
ដូចមីងនឹងអីនឹងពឹងវាមិនសូវបានទេនឹង
បើយើងចង់ទិញអីគេមួយចឹងទាល់តែប្តីគេអនុញ្ញាតិអោយទិញបានគេហ៊ានទិញចឹងទៅ
រាល់ថ្ងៃនឹងខ្វះជីវភាពណាស់

កៈ  ចុះអ៊ំគិតថាអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរទៅ?

ខៈ  ខ្ញុំធ្វើតែស្រែទេនៅផ្ទះនឹងហោស

កៈ  ចឹងធ្វើតែស្រែទេហោសអ៊ុំ?

ខៈ  រួចទៅទៅស៊ីឈ្នួលគេដូចអ្វីដែរខ្ញុំប្រាប់ចឹងហាស

កៈ  អូ៎!បាទអ៊ុំចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខៈ  ធម្មតាទេខ្ញុំនឹង

កៈ  លក្ខណៈថាស្ងោរ ឆា ការី?

ខៈ  ធម្មតាទេ
គេស៊ីអីកើតខ្ញុំក៏ស៊ីបានដែរនឹងដល់ពេលឥឡូវនឹងយើងមិនសូវមានធ្មេញហោសចឹងទាល់តែធ្វើអោយខ្លួនឯងអោយផុយចឹងហាស ចុះធ្មេញបាក់ហើយមិនមានលុយដាក់ផងនឹង

កៈ  ចុះល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងពីក្មេងហាស

ខៈ  កាលពីក្មេងហោស?

កៈ  ដូចជាចោលឈូងអីនឹង?

ខៈ  លេងភូមិរបស់ខ្ញុំនឹង នឹងលេងពេលចូលឆ្នាំទេណាស់លេងរាំវង្សទៅ
លេងរាំសារ៉ាវ៉ាន់ទៅ លេងចោលឈូងទៅ លេងអង្គុញទៅ

កៈ  អូ៎!បោះអង្គុញ ទាញព្រាត លាក់កន្សែងអីនឹងហោសអ៊ុំ?

ខៈ  នឹងហើយៗលេង នឹងហើយប្រពៃណីខ្មែរយើងលេងចឹងនឹងហើយ
រាំងវង្សអីចឹងទៅពួកខ្ញុំគ្រាន់លេង ចឹងៗនឹងណាស់

កៈ  ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខៈ  អត់ចេះច្រៀងផងនឹង

កៈ  ហ៎ោ!អ៊ុំដាក់មួយបទទៅអ៊ុំ?

ខៈ  ហ៎ោ!អត់ចេះទេមិនដឹងច្រៀងថាម៉េចទេនឹង នេះកូនរបស់ខ្ញុំនឹងចេះ

កៈ  បងចេះច្រៀងហោស?

ខៈ  អូ៎!បើច្រៀងវិញមិនបាច់និយាយទេ

កៈ  ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេ?

ខៈ  ឥឡូវនឹងយើងសម៉ាទានហើយយើងមិនសូវទេនឹង

កៈ  ប៉ុន្តែពីមុនអ៊ុំចូលចិត្តទេ?

ខៈ  ខ្ញុំចូលចិត្តតើ!

កៈ  លក្ខណៈអ៊ុំចូលចិត្តបទពីដើម រឺមួយបទសម័យដែរអ៊ុំ?

ខៈ  បទពីដើមខ្ញុំមិននិយាយលាក់ទេណាស់
ខ្ញុំនិយាយតាមត្រង់នឹងខ្ញុំចូលចិត្តតែបទប្រពៃណីនឹងកាលពី
ដើមនឹងចូលចិត្តបទប្រពៃណីហាស
ដល់ពេលឥឡូវនឹងយើងសម៉ាទានហើយចឹងកុំអោយគេថាអោយចឹង ហាសណាស់

កៈ  អូ៎!ចឹងហោសអ៊ុំ?

ខៈ  កុំអោយគេថាហ៎ោ!ចាស់ក្បាលហើយនៅស្តាប់ចំរៀង
នេះទូរទស្សន៍អីនឹងចំរៀងខ្លះខ្ញុំចូលចិត្តមើល ដែរតើនឹង
ប៉ុន្តែគ្រាន់តែបើគេច្រៀងមិនសូវពិរោះអីនឹងយើងមិនសូវមើលអីទៅណាស់

កៈ ចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ដែរទេអ៊ុំ?

ខៈ អត់មានទេ

កៈ សូម្បីតែបងប្អូនជីដូនមួយអីក៏អត់មានដែរ?

ខៈ អត់មានទេនឹង គ្មានពីណាមានទេនឹង

កៈ
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ ដូចថាពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងយ៉ាងម៉េចចឹងណាស់?

ខៈ ពីដើមមកផ្ទះមាន2ខ្នង ដល់ពេលហើយខ្មែរយួនចូលមកគេបានដុតឆេះអស់ទៅ ឥឡូវនឹងខ្ញុំនៅផ្ទះតូចមួយនឹង

កៈ ចុះឥឡូវនឹងផ្ទះយ៉ាងម៉េចដែរទៅ?

ខៈ នឹងផ្ទះនឹង នឹងខ្ទមនឹង ចុះកាលណុងអាវងងដឹងហើយមែនទេ
ខ្ញុំមិនទៅនៅផ្ទះនៅមាត់ទន្លេហើយខ្ញុំ លក់បានខ្លះ
ហើយមកធ្វើផ្ទះនៅនឹងអស់10000$ទៅមកចែកកូនចៅទៅ រាល់ថ្ងៃនឹងគ្មានលុយទេអស់រលីងតែម្តងនឹង

កៈ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំមួយនឹងគិតថាអ៊ុំសាងសងដោយខ្លួនឯង រឺក៏អ៊ុំជួលគេធ្វើដែរអ៊ុំ?

ខៈ ផ្ទះនឹងយើងទិញគេស្រាប់នឹង

កៈ អូ៎!យើងទិញគេស្រាប់តែម្តងនឹងហោសអ៊ុំ?

ខៈ នឹងហើយយើងទិញគេស្រាប់នឹង

កៈ ចឹងដូចជាប្តីរបស់អ៊ុំនឹងគាត់ចេះធ្វើផ្ទះដែរទេអ៊ុំ?

ខៈ គាត់ចាស់ហើយនឹងអាយុប៉ែតជាងហើយនឹង

កៈ ចុះពីមុនគាត់ចេះធ្វើផ្ទះដែរទេអ៊ុំ?

ខៈ ចេះដែរតើនឹង ពីមុននឹងគាត់ធ្វើនេះទូ តុ អីនឹងគាត់ជាអ្នកធ្វើតើពីមុននឹង
ប៉ុន្តែគាត់ធ្វើជាមួយគេទេណាស់

កៈ បាទអ៊ុំបាទ?

ខៈ គាត់មិនមែនជាជាងដោយខ្លួនឯងទេនឹង
ដូចថាអារ៉ាឯងជាជាងហើយខ្ញុំជាជំនួយជួយចឹងទៅ
ហុចនេះហុចនោះសំរាប់អោយគេធ្វើចឹងទៅណាស់ ធ្វើតុ ទូ អីដូចថាធ្វើជាមួយគេចឹងទៅ
ដល់ពេលឥឡូវនឹងដល់អាយុគាត់86-87ឆ្នាំហើយដល់ពេលចឹង
គាត់រៀងញ័រហើយគាត់ធ្វើអីលែងកើត ហើយនឹងណាស់

កៈ អូ៎!បាទជុំ
ចុះអ៊ុំគិតថាឪពុកម្តាយរបស់អ៊ុំគាត់មានធ្លាប់បង្រៀនពីជំនាញអីមួយទៅអ៊ុំដែរទេអ៊ុំ?

ខៈ អត់ទេនឹងមិនដែរទេ

កៈ ចុះលក្ខណៈថាអ៊ុំមានចេះជំនាញអីដោយខ្លួនឯងដែរទេអ៊ុំ?

ខៈ ខ្ញុំអត់មានចេះអីទេខ្ញុំស្រីហោស កាលណុងខ្ញុំគ្មានគិតអីទេ
បើងរបស់ខ្ញុំគាត់ប្រុសគាត់បានរៀនបួស ធ្វើជាលោកបានគាត់ចេះដឹង
អូអក្សរគាត់ច្បាស់លាស់ណាស់ ប៉ុន្តែគាត់បានស្លាប់បាត់ទៅហើយនឹង

កៈ ប៉ុន្តែលក្ខណៈថាជំនាញដូចជាកូរស្ករ កូរស្ករត្នោតលក្ខណៈធ្វើផ្តៅ វេញវល្លិ៍
រឺមួយធ្វើម្ហូបដែរអ៊ុំគិតថាចេះចឹងហាសអ៊ុំ?

ខៈ ឪពុករបស់ខ្ញុំនឹងឡើងត្នោតនឹងគាត់មិនដែរអោយយើងកូរទេ
បើអោយយើងយកទៅលក់ដែលនឹង
ដូចថាទឹកត្នោតអីអោយយើងរែកយកទៅលក់អីចឹងបើអត់ធ្វើស្ករនឹង
រែកទឹកត្នោតយកទៅលក់អោយចាម អីចឹងទៅណាស់

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ ចុះកាលណុងមួយបំពង់2រៀលនឹង កាលពីជំនាន់ណុងនឹង
មិនមែនដូចយើងមួយទយទេ ខ្ញុំយករែកទៅលក់បានមួយថ្ងៃ4-10រៀលនឹងហោស
ចុះពីដើមនឹងលុយថ្លៃហោស

កៈ ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរលំបាកជាងគេនៅក្នុងជីវិតរបស់អ៊ុំដែរចឹង
តាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខ៖ បច្ចុប្បន្ននឹង

ក៖ ចឹងមានន័យថាពិបាកជាងគេពេលដែរបច្ចុប្បន្ននឹងហោសអ៊ុំ?

ខ៖ នឹងហើយ

ក៖ អ៊ុំពិបាករឿងអីគេខ្លះដែរទៅអ៊ុំ?

ខ៖ ពិបាករឿងអីៗនឹង ដូចជាពិបាកតាំងពិលុយចាយ ពិបាកតាំងពីម្ហូបស៊ីនឹងណាស់ ទាល់តែយើងមាន លុយបានយើងម្ហូបណាស់អាវ៉ា នឹងពិបាកត្រង់នឹងរាល់ថ្ងៃនឹងណាស់

ក៖ ចុះង៉ុំគិតថាតាំងពីក្មេងនឹងអ៊ុំមានការលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខ៖ អត់ពិបាកទេនឹង

ក៖ អ្ហូ!ចឹងពីក្មេងអ៊ុំអត់មានការលំបាកអីទេ?

ខ៖ អត់ទេពីក្មេងនឹងស្រណុកណាស់ខ្ញុំហោស

ក៖ ចុះរហូតដល់ជំនាន់ពលពតនឹងអ៊ុំលំបាកអីគេខ្លះដែរអ៊ុំ?

ខ៖ អត់មានលំបាកអីសោះ

ក៖ ចឹងអ៊ុំអត់ដែរលំបាកផងហោសអ៊ុំ?

ខ៖ អត់សោះដូចថាយើងចាស់ៗ
មីងៗចឹងគេអោយយើងទៅត្បាញកន្ទេលហាស2ថ្ងៃគេយកមួយៗៗ
គេយករំចេកអោយយើងមកត្បាញ ស្គាល់រំចេកទេអាវ៉ា?

ក៖ អត់ស្គាល់ទេអ៊ុំ

ខ៖ ហើយបាយគេអោយយើងស៊ីគ្រប់គ្រាន់នឹង
ជំនាន់ពអាពតនឹងមិនខ្វះស៊ីទេនឹងចឹងខ្ញុំអត់ពិបាកទេ ខ្ញុំពិបាកពេលខ្ញុំមកនៅនេះនឹង
ចឹងបានគេថាជួយបង្ហោះអោយហ៊ុនសែនអីជួយផងនឹង ខ្ញុំធ្លាប់ទៅជាមួយហ៊ុនសែនដែរតើ
ប៉ុន្តែឥឡូវនឹងគេលែងស្គាល់យើងហើយនឹងណាស់

ក៖ បាទចឹងហោសអ៊ុំបាទ?

ខ៖
ឥឡូវនឹងកើតអីបានជាគេមិនស្គាល់ពីព្រោះក្នុងមួយប្រទេសនឹងគាត់មើលយើងមិនគ្រប់ទេមិនចឹង យើងនឹងក្នុងមួយប្រទេសនឹងគាត់មើលយើងវាមិនចំទៅ

ក៖ បាទអ៊ុំត្រូវហើយអ៊ុំ?

ខ៖ គេថាអោយង្គោះទៅណាស់
យើងមិនចេះតែបង្គោះទេបើមិនមានខ្សែរយះដាច់ងស់ហើយនឹង
ដូចជាស៊ីមការអីនឹងទៅនៅភ្នំពេញអស់ហើយនឹង សុទ្ធតែខ្សែរយះជាមួយគ្នានឹងណាស់

ក៖ អូ៎!ចឹងអ៊ុំស្គាល់អ្នកធំដែរហោសអ៊ុំ?

ខ៖ មានហ៊ុនសែន នឹងហេងសំរិណអីនឹងសុទ្ធនៅជាមួយខ្ញុំហើយនឹងហោស
ដូចថាឆ្នាំណានោះខ្ញុំបាន ទៅផ្ទះគុនគីមចឹងទៅខ្ញុំមើលឃើញគេចឹង
ប៉ុន្តែគេអោយចូលហាស

ក៖ ផ្ទះរបស់គុនគិមហោសអ៊ុំ?

ខ៖ នឹងហើយនៅតាខ្មៅហោស គេថាអត់នៅទេ ចុះឆ្នាំនោះគេមិនអង្គុញនៅលើផ្ទះគេហើយនឹងគេបាន ឈរពាក់សារ៉ុងសូត្រហាស
គេថាអត់នៅទេហើយអត់អោយចូលទៀតនឹង

ក៖ ផ្ទះគុនគីមនឹងត្រូវអីគេនឹងអ៊ុំដែរ?

ខ៖ នឹងដូចថាវាគ្មានសាច់ញ្ញាតិអីទេយើងគ្រាន់តែរាប់អានគ្នាកាលពីនៅកំពង់ចាមនេះនឹងកាលណុងខ្ញុំកាន់ឃ្លាំងពាណិជ្ជកម្មនោះ នឹងហើយគេរាក់ទាក់យើងហាសណាស់

ក៖ អូ៎!ចឹងទេហោសអ៊ុំ?

ខ៖ ខ្ញុំប្រាប់អារវឯង
ឪថៅហ្វាយស្រុកកំពង់សៀមយើងនឹងអីនឹងកាលពីខ្ញុំកាន់ឃ្លាំងនឹងមួយថ្ងៃគេទៅ2-3ដងនឹងណាស់
ដល់ពេលឥឡូវនឹងខ្ញុំមកនៅនឹងគេធ្វើថៅហ្វាយស្រុកហាសគេមិនបានស្គាល់យើងទេ

ក៖ អូ៎!គេធ្វើភ្លេចយើងហោស?

ខ៖ នឹងយើងគេមិនស្គាល់យើងទេនឹងហើយខ្ញុំក៏មិនតូចចិត្តដែរ កូនរបស់ខ្ញុំនឹងគេថាម៉ែគេមិនស្គាល់ក៏អត់ ទៅណាស់មិនចឹង

ក៖ បាទអ៊ុំបាទត្រូវហើយអ៊ុំ?

ខ៖ នឹងហើយវាចឹង

ក៖ ចុះអ៊ុំគិតថាកាលពីជំនាន់ពលពតនឹងគេជំលាសអ៊ុំទៅណាដែរទៅ?

ខ៖ កាលពីជំនាន់ពលពតនឹងខ្ញុំនៅស្រុកតំប៉ែមិនបាកជំលាសទេ ខ្ញុំចេញខ្លួនឯងនឹងខ្ញុំតស៊ូ

ក៖ ចេញទៅនៅណាដែរទៅអ៊ុំ?

ខ៖ ចេញពីស្រុកតំប៉ែនឹងទៅដល់យួនហោសនៅឆ្នាំ1977ចេញទៅដល់ស្រុកយួនហោសទៅដល់ តាយនឹងហាស

ក៖ ចឹងមានន័យថាអ៊ុំលេងនៅខ្មែរហើយ អ៊ុំទោនៅតាយនឹងវិញហោសអ៊ុំ?

ខ៖ នឹងហើយដូចថាពេលដែរយើងរំដោះហើយឆ្នាំ1979ហោស មិនតាឈួននឹងមិនដឹកយើងមកវិញ

ក៖ ចុះគេបើកផ្លូវអើយអ៊ុំចូលទៅដែរហោសអ៊ុំ?

ខ៖ ចុះបើមិនបើកយើងមានកាំភ្លើង ចុះបើមិនបើកនឹងបាញ់ទៅនឹកឃើញចឹងចុះកាន់កាំភ្លើងរៀងខ្លួន ហើយនឹងមានគ្នា100នាក់ នឹងមានកាំភ្លើងគ្រប់ដៃដែរនឹង ខ្ញុំក៏ដោយ គេក៏ដោយ ឪក៏ដោយនឹងកាន់កាំភ្លើង កាន់កូនខ្មោច ពួកនារិតីខ្ញុំប្រាប់ តែមិនបាច់អោយចុលក្នុងនឹងទេហី?

ក៖ អត់អីទេអ៊ុំ

ខ៖ ពួកនារិតីវាឃើញខ្ញុំវាបាញ់ខ្ញុំហាស យើងឃើញវាយើងបាញ់វាយើងនឹងកាន់កូនខ្មោចគ្រប់គ្នាវាដើររក យើងនឹងហើយយើងពួន ដូចថាវារកយើងដូចថាវាមានគ្នា6នាក់ចឹងវារកយើងវាដើរមួយក្រុមហាស ហើយមានកាំភ្លើងគ្រប់ដៃដែរហើយវាឃើញយើងវាមិនបាញ់យើង ហើយយើងឃើញយើងមិនបាញ់វា អានឹងវាចឹង

ក៖ ចុះម៉េចទៀតទៅអ៊ុំ?

ខ៖ យើងកាន់កូនខ្មោចរៀងខ្លួននឹង

ក៖ ចង់និយាយថាឃើញគ្នាបាញ់គ្នារៀងខ្លួនទៅអ៊ុំ?

ខ៖
នឹងហើយឃើញគ្នាបាញ់គ្នារៀងខ្លួនដល់ពេលវាឃើញយើងវាភ្លើលយើងចឹងវារត់ទៅប៉ុន្តែយើងមិន បាញ់វាអោយស្លាប់ទេណាស់

ក៖ យើងលក្ខណះបាញ់ប្រហើរចោលចឹងហោសអ៊ុំ?

ខ៖ នឹងហើយយើងឃើញវាចឹងបាញ់ចោលនឹង
ប៉ុន្តែវាឃើញយើងវិញវាបាញ់យើងសំលាប់តែម្តងនឹង

ក៖ អូ្!ខ្លាំងហាសណាអ៊ុំ?

ខ៖ នឹងហើយពួកតាកេរនឹងវាស្អប់ណាស់ វាថាទុកផ្ទះអោយខ្មោចនៅ
ទុកផ្លូវអោយឆ្កែដើរនឹង

ក៖ អូ្!បាទគេនិយាយចឹង?

ខ៖ នឹងហើយមួយជំនាន់ណុងអារវងងមិនទាន់ទេខ្ញុំបានទាន់នឹងហើយ
អារវងក៏ទាន់នៅពីតូចដែរនឹង

ក៖ ប្រហែលជាឆ្នាំណាដែរអ៊ុំ?

ខ៖ វាបាច់ប្រាក់នឹងនៅឆ្នាំ1978

ក៖ អូ្!ខ្ញុំមិនទាន់ទេនឹងអ៊ុំខ្ញុំនៅឆ្នាំកៅជាងហើយនឹងអ៊ុំ?

ខ៖
ឆ្នាំ1978នឹងបេញអំណាចតែម្តងនឹងវាសំលាប់ទាំងគ្រួសារនឹងតែម្តងនឹងបងរបស់ខ្ញុំនឹងចាញ់ប្រស្នាគេ នឹងបានគេសំលាប់ទាំងគ្រួសារនឹងបងស្រីរបស់ខ្ញុំនឹងបងទី3ហាស

ក៖ បាទយ៉ាងម៉េចទោអ៊ុំ?

ខ៖ វាបោកប្រាស់ចេះវាថាកាលណុងវាចាប់តាំងប្ដីអោយធ្វើកងតូច
កងធំហោសដល់ពេលចឹងវាយកប្ដី នឹងទៅរៀនហាស
ហើយខ្ញុំនឹងហាសចុះកាលណុងយើងមានទូរស័ព្ទដុចឥឡូវនឹងណាមែនទេ?

ក៖ បាទត្រូវហើយអ៊ុំ

ខ៖ ខ្ញុំបានសរសេរសំបុត្រហាស
ម្ដាយរបស់ខ្ញុំទៅលេងខ្ញុំហើយខ្ញុំបានសរសេរសំបុត្រថាបើវាយកបង
នឹងទៅវាយកទៅសំលាប់ហើយគ្មានយកទៅរៀនទេនឹង

ក៖ បាទអ៊ុំចឹង?

ខ៖ ខ្ញុំដាក់ក្នុងអក្សររបស់ខ្ញុំប៉ុន្តែកាលណុងខ្ញុំសរសេរកើតហាស
ហើយបងឯងបើវាមកហៅកុំទៅអោយ សោះនឹងណាស់បើទៅវាប្រាកដជាបោកប្រាស់ថា

ក៖ វាយកទៅសំលាប់ចោលហោសអ៊ុំ?

ខ៖ អត់ទេវាយកបងឯងទៅជួបប្ដីបងឯងនៅស្វងនឹង
ដល់វាយកមកវៃយើងនៅព្រះវិហារយេស៊ូយើងនឹង
នៅជិតជប់នេះយកមកវៃនៅនឹងវៃអស់មួយសំបុក មានកូន3នាក់
ហើយនឹងម៉ែឪទៀតវាអស់5នាក់នឹង យកវៃចោលទាំងអស់នឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ នឹងហោសដូចថាយើងខ្វះជីវភាពខ្វះខាតដូចជាលុយ នឹងអង្ករអីចឹងហាស
យើងខ្វះស៊ីដូចជាម្ហូបអី ចឹងទៅណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ នឹងខ្ញុំខ្វះចឹងឯង

ក៖
ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ
ទៅ ដូចថាលក្ខណះថាអីមួយចឹង?

ខ៖ ដូចថាពេលដែរយើងសប្បាយមានរបស់របរស៊ីចាយ
ដូចថាកូនមានដឹងម៉ែដឹងឪចឹងហាស
នឹងមានលក្ខណៈថាដូចជាសប្បាយវិញហើយនឹងជឿទេ?

ក៖ បាទត្រូវហើយអ៊ុំ

ខ៖ នឹងហើយនឹងជាលក្ខណៈសប្បាយដូចថាកូនដឹងម៉ែដឹងឪចឹងទៅ
ដូចអាវិនអីចឹងបើមានការងារធ្វើ ហាសម៉ែឪសប្បាយតាមនឹងដែរ
ក៏ខ្ញុំពិបាកនឹងរាល់តែថ្ងៃនឹងពិបាកដោយសារតែវានឹងតើ!

ក៖ ម៉េចទៅអ៊ុំ?

ខ៖ ហើយបងៗគេចេះតែដៀលខ្ញុំថាបានជាម៉ែឯងអោយវាស៊ី
មកពីម៉ែឯងអោយវាចាយនឹងបានវាមិនធ្វើ ការងារអីហោស

ក៖ គាត់និយាយថាអោយអ៊ុំចឹង?

ខ៖ នឹងហើយគេដៀលយើងចឹងណាស់ មីនឹងមីយកប្តីចាមនឹងហាសអត់ស្តាប់យើងទេ

ក៖ ចុះអ៊ុំធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំធ្លាប់ធ្វើអីគេដែរទេ?

ខ៖ ម៉ែរបស់ខ្ញុំនឹងមិនអោយរៀនទេនឹងកូនស្រីកាលពីជំនាន់ខ្ញុំនឹងណោះ

ក៖ ម៉េចចឹងហោសអ៊ុំ?

ខ៖ គេថាចេះកុំរៀន ថាគួចហាសកុំអោយក្បួបរៀននឹងអ្នកស្រុកគ្នាឯងទេណាស់
ពេលដែរវារៀនចឹងទៅវា ចេះសរសេរសំបុត្រឆ្លើយឆ្លងប្រុសអី
អូវាយកគ្នាយ៉ាងព្រៃផ្សៃអីណា

ក៖ អូ៎!គេនិយាយចឹងហោសអ៊ុំ?

ខ៖ ចឹងគាត់មិនអោយរៀនរហូតនឹង
ខ្ញុំចេះដោយសារតែបងប្រុសរបស់ខ្ញុំនឹងបួសធ្វើលោកទេនឹង

ក៖ បាទចឹងអ៊ុំ?

ខ៖
មិនអោយរៀនទេជំនាន់ខ្ញុំនោះបើបងៗរបស់ខ្ញុំប្រុសៗនឹងហាសអូរៀនដល់ណាក៏អោយរៀនដែរនឹង

ក៖ ចឹងមានន័យថាបងប្អូនរបស់អ៊ុំបានរៀន ប៉ុន្តែអ៊ុំមិនបានរៀនទេនឹង?

ខ៖ បានរៀនតែបងប្រុសមួយនឹង

ក៖ អូ៎!បងប្រុសធំនឹងហោសអ៊ុំ?

ខ៖ ចា៎!បងស្រី3នាក់នឹងចេះមីកណ្ដាលចេះដែរខ្ញុំថាអាពតយកទៅវៃចោលនឹងណាស់ នឹងខ្ញុំចេះបាន មើលនឹងបានអានដូចគ្នាអីចឹង បើមីរាល់ថ្ងៃនឹងមិនចេះសោះនឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ ប៉ុន្តែឥឡូវនឹងគេស្ពាក់ធិមទី8ហើយនឹង គេកាន់សិល្ប៍8ហើយរាល់ថ្ងៃនឹងនោះ

ក៖
ចុះបើគិតថាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរអ៊ុំ?

ខ៖ ខ្ញុំចង់និយាយថាកូនជំនាន់ក្រោយៗនឹងអោយយើងជៀសផុតពីគ្រឿញៀនហាស
អោយយើងចេះ ថែរក្សាគ្នាកុំអោយវៃគ្នា
នឹងកុំអោយយើងកាប់សំលាប់គ្នាអោយយើងសាងអនាគត់ទៅ អ្នកឯងទាំងអស់
គ្នានឹងជាខ្នងទំពាំងឬស្សីនឹងហើយនឹង
អោយចេះស្រលាញ់គ្នាពីព្រោះតែយើងជាខ្មែរណាស់អា៎

ក៖ បាទត្រូវហើយអ៊ុំ?

ខ៖ អោយចេះស្រលាញ់គ្នានឹង
សូម្បីតែបរទេសក៏ដោយក៏មិនអោយយើងចេះរើសអើងអីដែរនឹង
អើយយើងចេះគោរពគ្នាទៅវិញទៅមកអោយយើងចេះស្រលាញ់គ្នាទៅមិនថានៅប្រទេសណាៗទេអោយតែយើងស្រលាញ់គ្នាណ

ក៖ បាទអ៊ុំល្អអ៊ុំ?

ខ៖ នឹងហើយខ្ញុំជូនពរតែចឹងអោយបានសុខភាពល្អនឹងហើយ

កៈ  ចឹងអ៊ុំមានអីចង់ផ្ដែផ្ដាំអីទៅផ្សេងទៀតទេអ៊ុំ?

ខៈ  ផ្ដែផ្ដាំអីទៅទៀតហោសមិនដឹងនិយាយថាម៉េចទៀតទេនឹង

កៈ  អ៊ុំអត់មានអីទៀតទេណាអ៊ុំ?

ខៈ  ចា៎!នឹងហើយប៉ុណ្ណឹងបានហើយនឹង

កៈ  ចឹងខ្ញុំអរគុណពីប្រវត្តិរបស់អ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយខ្ញុំនឹងដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាអ៊ុំ

ខៈ  នឹងហើយ

កៈ
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗរបស់អ៊ុំអោយពួកគាត់បានស្គាល់នឹងបានស្ដាប់ពីសំលេងរបស់ អ៊ុំដែរអ៊ុំបានមកពិភាក្សាជាមួយខ្ញុំចឹងហាសអ៊ុំ?

ខៈ  ចា៎!នឹងហើយ

កៈ  បាទចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំ
ហើយខ្ញុំជូនពរអ៊ុំដូចគ្នាដើម្បីអោយមានសុខភាពល្អចឹងហាសអ៊ុំ?

ខៈ  ចា៎!ទៅណា មកណាអោយមានសុវត្ថិភាព

កៈ  បាទអរគុណច្រើនអ៊ុំ៕៕៕